ក) ស្រាយថា $\dfrac{\sin a}{1+2\cos 2a}=\dfrac{1}{4}\left(\dfrac{3}{\sin 3a}-\dfrac{1}{\sin a}\right)$

គេបាន $\dfrac{3}{\sin 3a}-\dfrac{1}{\sin a}=\dfrac{3-(3-4\sin^2 a)}{\sin 3a}=\dfrac{4\sin^2 a}{\sin 3a}$

ដោយ $\sin 3a=3\sin a-4\sin^3 a=\sin a(3-4\sin^2 a)$

$$=\sin a\left[1+2(1-2\sin^2 a)\right]=\sin a(1+2\cos a)$$

ដូចនេះ: $\dfrac{\sin a}{1+2\cos 2a}=\dfrac{1}{4}\left(\dfrac{3}{\sin 3a}-\dfrac{1}{\sin a}\right)$ ។

ខ)គណនាផលបូក ៖

$$S_n = \frac{\sin a}{1+2\cos 2a} + \frac{\frac{1}{3}\sin\frac{a}{3}}{1+2\cos\frac{2a}{3}} + \ldots\ldots \frac{\frac{1}{3^n}\sin\frac{a}{3^n}}{1+2\cos\frac{2a}{3^n}}$$

គេមាន $\frac{\sin a}{1+2\cos 2a} = \frac{1}{4}\left(\frac{3}{\sin 3a} - \frac{1}{\sin a}\right)$ ជំនួស a ដោយ $\frac{a}{3^k}$

រួចគុណអង្គទាំងពីរនឹង $\frac{1}{3^k}$ គេបាន ៖

$$\frac{\frac{1}{3^k}\sin\frac{a}{3^k}}{1+2\cos\frac{2a}{3^k}} = \frac{1}{4}\left(\frac{1}{3^{k-1}}\cdot\frac{1}{\sin\frac{a}{3^{k-1}}} - \frac{1}{3^k}\cdot\frac{1}{\sin\frac{a}{3^k}}\right)$$

$$S_n = \sum_{k=0}^{n}\frac{\frac{1}{3^k}\sin\frac{a}{3^k}}{1+2\cos\frac{2a}{3^k}} = \frac{1}{4}\sum_{k=0}^{n}\left(\frac{1}{3^{k-1}}\cdot\frac{1}{\sin\frac{a}{3^{k-1}}} - \frac{1}{3^k}\cdot\frac{1}{\sin\frac{a}{3^k}}\right)$$

ដូចនេះ $S_n = \frac{1}{4}\left(\frac{3}{\sin 3a} - \frac{1}{3^n\sin\frac{a}{3^n}}\right)$ ។

លំហាត់ទី១៨

គណនាផលបូកខាងក្រោម ៖

$$S_n=\sum_{k=0}^{n}\left(\frac{1}{3^k}\sin^3 3^k a\right)=\sin^3 a+\frac{1}{3}\sin^3 3a+\ldots+\frac{1}{3^n}\sin^3 3^n a$$

ដំណោះស្រាយ

គណនាផលបូក ៖

$$S_n=\sum_{k=0}^{n}\left(\frac{1}{3^k}\sin^3 3^k a\right)=\sin^3 a+\frac{1}{3}\sin^3 3a+\ldots+\frac{1}{3^n}\sin^3 3^n a$$

តាមរូបមន្ត $\sin 3x = 3\sin x - 4\sin^3 x$

នោះគេទាញ $\sin^3 x=\frac{1}{4}\left(3\sin x-\sin 3x\right)$

គេបាន $S_n=\sum_{k=0}^{n}\left(\frac{1}{4\cdot 3^k}\left(3\sin 3^k a-\sin 3^{k+1}a\right)\right)=\frac{1}{4}\sum_{k=0}^{n}\left(\frac{1}{3^{k-1}}\sin 3^k a-\frac{1}{3^k}\sin 3^{k+1}a\right)$

ដូចនេះ $S_n=\frac{1}{4}\left(3\sin a-\frac{1}{3^n}\sin 3^{n+1}a\right)$ ។

លំហាត់ទី១៩

គណនាផលបូកខាងក្រោម ៖

$$S_n = \sum_{k=0}^{n}\left((-3)^k \cos^3 \frac{a}{3^k}\right) = \cos^3 a - 3\cos^3 \frac{a}{3} + \dots + (-3)^k \cos^3 \frac{a}{3^k}$$

ដំណោះស្រាយ

គណនាផលបូកខាងក្រោម ៖

$$S_n = \sum_{k=0}^{n}\left((-3)^k \cos^3 \frac{a}{3^k}\right) = \cos^3 a - 3\cos^3 \frac{a}{3} + \dots + (-3)^k \cos^3 \frac{a}{3^k}$$

តាមរូបមន្ត $\cos 3x = 4\cos^3 x - 3\cos x$

នោះគេទាញ $\cos^3 x = \frac{1}{4}(3\cos x + \cos 3x)$

$$S_n = \sum_{k=0}^{n}\left((-3)^k \cos^3 \frac{a}{3^k}\right) = \frac{1}{4}\sum_{k=0}^{n}\left[(-3)^k \cos\frac{a}{3^{k-1}} - (-3)^{k+1}\cos\frac{a}{3^k}\right]$$

ដូចនេះ $S_n = \frac{1}{4}\left[\cos 3a - (-3)^{n+1}\cos\frac{a}{3^n}\right]$ ។

លំហាត់ទី២០

គណនាផលគុណខាងក្រោម ៖

$$P_n = \cos a \times \cos 2a \times \cos 2^2 a \times \ldots \times \cos 2^n a$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម

$$P_n = \cos a \times \cos 2a \times \cos 2^2 a \times \ldots \times \cos 2^n a$$

តាមរូបមន្ត $\sin 2\varphi = 2\sin\varphi\cos\varphi$

គេទាញ $\cos\varphi = \frac{1}{2}\cdot\frac{\sin 2\varphi}{\sin\varphi}$

គេបាន $P_n = \frac{1}{2}\cdot\frac{\sin 2a}{\sin a}\times\frac{1}{2}\cdot\frac{\sin 4a}{\sin 2a}\times\frac{1}{2}\cdot\frac{\sin 8a}{\sin 4a}\times\ldots\times\frac{1}{2}\cdot\frac{\sin 2^{n+1}a}{\sin 2^n a}$

ដូចនេះ $P_n = \frac{1}{2^n}\times\frac{\sin 2^{n+1}a}{\sin a}$

លំហាត់ទី២១

គណនាផលគុណខាងក្រោម ៖

$$P_n=(1-\tan^2 a)(1-\tan^2 2a)(1-\tan^2 2^2 a)....(1-\tan^2 2^n a)$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$P_n=(1-\tan^2 a)(1-\tan^2 2a)(1-\tan^2 2^2 a)....(1-\tan^2 2^n a)$$

តាមរូបមន្ត $\tan 2\varphi=\dfrac{2\tan\varphi}{1-\tan^2\varphi}$

គេទាញ $1-\tan^2\varphi=2\times\dfrac{\tan\varphi}{\tan 2\varphi}$

គេបាន $P_n=2.\dfrac{\tan a}{\tan 2a}\times 2.\dfrac{\tan 2a}{\tan 4a}\times 2.\dfrac{\tan 4a}{\tan 8a}\times ...\times 2.\dfrac{\tan 2^n a}{\tan 2^{n+1}a}$

ដូចនេះ $P_n=2^n\times\dfrac{\tan a}{\tan 2^{n+1}a}$ ។

លំហាត់ទី២២

គណនាផលគុណខាងក្រោម ៖

$$P_n = (1+2\cos 2a)(1+2\cos\frac{2a}{3})(1+2\cos\frac{2a}{3^2})...(1+2\cos\frac{2a}{3^n})$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$P_n = (1+2\cos 2a)(1+2\cos\frac{2a}{3})(1+2\cos\frac{2a}{3^2})...(1+2\cos\frac{2a}{3^n})$$

តាមរូបមន្ត $\sin 3\varphi = 3\sin\varphi - 4\sin^3\varphi = \sin\varphi(3-4\sin^2\varphi)$

ដោយ $3-4\sin^2\varphi = 1+2(1-2\sin^2\varphi) = 1+2\cos 2\varphi$

គេទាញ $1+2\cos 2\varphi = \dfrac{\sin 3\varphi}{\sin\varphi}$

គេបាន $P_n = \dfrac{\sin 3a}{\sin a} \times \dfrac{\sin a}{\sin\frac{a}{3}} \times \dfrac{\sin\frac{a}{3}}{\sin\frac{a}{3^2}} \times .... \times \dfrac{\sin\frac{a}{3^{n-1}}}{\sin\frac{a}{3^n}} = \dfrac{\sin 3a}{\sin\frac{a}{3^n}}$ ។

លំហាត់ទី២៣

គណនាផលគុណខាងក្រោម ៖

$$P_n=(2\cos 2a-1)(2\cos\frac{2a}{3}-1)(2\cos\frac{2a}{3^2}-1)...(2\cos\frac{2a}{3^n}-1)$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$P_n=(2\cos 2a-1)(2\cos\frac{2a}{3}-1)(2\cos\frac{2a}{3^2}-1)...(2\cos\frac{2a}{3^n}-1)$$

តាមរូបមន្ត $\cos 3\varphi=4\cos^3\varphi-3\cos\varphi=\cos\varphi(4\cos^2\varphi-3)$

ដោយ $4\cos^2\varphi-3=2(2\cos^2\varphi-1)-1=2\cos 2\varphi-1$

គេទាញ $2\cos 2\varphi-1=\dfrac{\cos 3\varphi}{\cos\varphi}$

គេបាន $P_n=\dfrac{\cos 3a}{\cos a}\times\dfrac{\cos a}{\cos\frac{a}{3}}\times\dfrac{\cos\frac{a}{3}}{\cos\frac{a}{3^2}}\times....\times\dfrac{\cos\frac{a}{3^{n-1}}}{\cos\frac{a}{3^n}}=\dfrac{\cos 3a}{\cos\frac{a}{3^n}}$ ។

លំហាត់ទី២៤

គណនា $P_n = (2\cos a - 1)(2\cos\frac{a}{2} - 1)(2\cos\frac{a}{2^2} - 1)...(2\cos\frac{a}{2^n} - 1)$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$P_n = (2\cos a - 1)(2\cos\frac{a}{2} - 1)(2\cos\frac{a}{2^2} - 1)...(2\cos\frac{a}{2^n} - 1)$$

តាមរូបមន្ត $\cos 2\varphi = 2\cos^2\varphi - 1$ នោះ $2\cos 2\varphi = 4\cos^2\varphi - 2$

គេទាញ $2\cos 2\varphi + 1 = 4\cos^2\varphi - 1 = (2\cos\varphi - 1)(2\cos\varphi + 1)$

នាំឲ្យ $2\cos\varphi - 1 = \dfrac{2\cos 2\varphi + 1}{2\cos\varphi + 1}$ ។ កន្សោម P_n អាចសរសេរ ៖

$$P_n = \frac{2\cos 2a + 1}{2\cos a + 1} \times \frac{2\cos a + 1}{2\cos\frac{a}{2} + 1} \times \frac{2\cos\frac{a}{2} + 1}{2\cos\frac{a}{2^2} + 1} \times ... \times \frac{2\cos\frac{a}{2^{n-1}} + 1}{2\cos\frac{a}{2^n} + 1}$$

ដូចនេះ $P_n = \dfrac{2\cos 2a + 1}{2\cos\frac{a}{2^n} + 1}$ ។

លំហាត់ទី២៥

គណនាផលគុណខាងក្រោម ៖

$$P_n=(1+\frac{8}{1-3\tan^2 a})(1+\frac{8}{1-3\tan^2\frac{a}{3}})...(1+\frac{8}{1-3\tan^2\frac{a}{3^n}})$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$P_n=(1+\frac{8}{1-3\tan^2 a})(1+\frac{8}{1-3\tan^2\frac{a}{3}})...(1+\frac{8}{1-3\tan^2\frac{a}{3^n}})$$

តាមរូបមន្ត $\tan 3a=\dfrac{3\tan a-\tan^3 a}{1-3\tan^2 a}=\dfrac{\tan a(3-\tan^2 a)}{1-3\tan^2 a}$

គេទាញ $\dfrac{\tan 3a}{\tan a}=\dfrac{3-\tan^2 a}{1-3\tan^2 a}=\dfrac{1}{3}+\left(\dfrac{3-\tan^2 a}{1-3\tan^2 a}-\dfrac{1}{3}\right)$

$$=\frac{1}{3}+\frac{8}{3(1-3\tan^2 a)}=\frac{1}{3}\left(1+\frac{8}{1-3\tan^2 a}\right)$$

នាំឲ្យ $1+\dfrac{8}{1-3\tan^2 a}=\dfrac{3\tan 3a}{\tan a}$

ជំនួស a ដោយ $\frac{a}{3^k}$ គេបាន $1+\frac{8}{1-3\tan^2\frac{a}{3^k}}=\frac{3\tan\frac{a}{3^{k-1}}}{\tan\frac{a}{3^k}}$

ចំពោះ $k=0:1+\frac{8}{1-3\tan^2 a}=\frac{3\tan 3a}{\tan a}$

ចំពោះ $k=1:1+\frac{8}{1-3\tan^2\frac{a}{3}}=\frac{3\tan a}{\tan\frac{a}{3}}$

ចំពោះ $k=2\ :\ 1+\frac{8}{1-3\tan^2\frac{a}{3^2}}=\frac{3\tan\frac{a}{3}}{\tan\frac{a}{3^2}}$

ចំពោះ $k=n:1+\frac{8}{1-3\tan^2\frac{a}{3^n}}=\frac{3\tan\frac{a}{3^{n-1}}}{\tan\frac{a}{3^n}}$

គុណទំនាក់ទំនងខាងលើអង្គ និង អង្គគេបាន ៖

$$P_n=\frac{3^n\tan 3a}{\tan\frac{a}{3^n}}=3^n\tan 3a\cot\frac{a}{3^n}$$ ។

លំហាត់ទី២៦

ក) ចូរគណនាតម្លៃប្រាកដនៃ $\sin\frac{\pi}{10}$ និង $\cos\frac{\pi}{10}$

ខ) ចូរស្រាយថា $x^2+(x-y)^2 \le 4(x^2+y^2)\sin^2\frac{\pi}{10}$

គ្រប់ចំនួន $x, y \in IR$ ។

ដំណោះស្រាយ

ក)គណនាតម្លៃប្រាកដនៃ $\sin\frac{\pi}{10}$ និង $\cos\frac{\pi}{10}$

គេមាន $\frac{2\pi}{10}=\frac{\pi}{2}-\frac{3\pi}{10}$

គេបាន $\sin\frac{2\pi}{10}=\sin(\frac{\pi}{2}-\frac{3\pi}{10})=\cos\frac{3\pi}{10}$

តាមរូបមន្តត្រីកោណមាត្រ ៖

$\sin 2a = 2\sin a\cos a$ និង $\cos 3a = 4\cos^3 a - 3\cos a$

$$2\sin\frac{\pi}{10}\cos\frac{\pi}{10}=\cos\frac{3\pi}{10}$$

$$2\sin\frac{\pi}{10}\cos\frac{\pi}{10}=3\cos\frac{\pi}{10}-4\cos^3\frac{\pi}{10}$$

$$2\sin\frac{\pi}{10}=3-4\cos^2\frac{\pi}{10}$$

$$2\sin\frac{\pi}{10}=3-4(1-\sin^2\frac{\pi}{10})$$

ឬ $4\sin^2\frac{\pi}{10}-2\sin\frac{\pi}{10}-1=0$ តាង $t=\sin\frac{\pi}{10}>0$

គេបាន $4t^2-2t-1=0$, $\Delta'=1+4=5>0$

គេទាញឫស $t_1=\frac{1-\sqrt{5}}{4}<0$, $t_2=\frac{1+\sqrt{5}}{4}$

ដូចនេះ $\sin\frac{\pi}{10}=\frac{1+\sqrt{5}}{4}$ ។ ដោយ $\sin^2\frac{\pi}{10}+\cos^2\frac{\pi}{10}=1$

នាំឲ្យ $\cos\frac{\pi}{10}=\sqrt{1-(\frac{1+\sqrt{5}}{4})^2}=\frac{\sqrt{10-2\sqrt{5}}}{4}$

ដូចនេះ: $\cos\frac{\pi}{10}=\frac{\sqrt{10-2\sqrt{5}}}{4}$ ។

ខ) ស្រាយថា $x^2+(x-y)^2 \le 4(x^2+y^2)\sin^2\frac{\pi}{10}$

តាងអនុគមន៍ $f(x;y)=x^2+(x-y)^2-4(x^2+y^2)\sin^2\frac{\pi}{10}$

គេបាន $f(x;y)=x^2+x^2-2xy+y^2-4(x^2+y^2)(\frac{1+\sqrt{5}}{4})^2$

$$=2x^2-2xy+y^2-4(x^2+y^2)\frac{6+2\sqrt{5}}{16}$$

$$=2x^2-2xy+y^2-(x^2+y^2)\frac{3+\sqrt{5}}{2}$$

$$=\frac{1-\sqrt{5}}{2}x^2-2xy-\frac{1+\sqrt{5}}{2}y^2$$

$$=-\left(\frac{\sqrt{5}-1}{2}x^2+2xy+\frac{\sqrt{5}+1}{2}y^2\right)$$

$$=-\left(\sqrt{\frac{\sqrt{5}-1}{2}}\,x+\sqrt{\frac{\sqrt{5}+1}{2}}\,y\right)^2\le 0$$

ដូចនេះ: $x^2+(x-y)^2 \le 4(x^2+y^2)\sin^2\frac{\pi}{10}$ ។

លំហាត់ទី២៧

ចូរស្រាយបញ្ជាក់ថា

$$\left(\frac{1}{2}+\cos\frac{\pi}{20}\right)\left(\frac{1}{2}+\cos\frac{3\pi}{20}\right)\left(\frac{1}{2}+\cos\frac{9\pi}{20}\right)\left(\frac{1}{2}+\cos\frac{27\pi}{20}\right)=\frac{1}{16}$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

តាង $P=\left(\frac{1}{2}+\cos\frac{\pi}{20}\right)\left(\frac{1}{2}+\cos\frac{3\pi}{20}\right)\left(\frac{1}{2}+\cos\frac{9\pi}{20}\right)\left(\frac{1}{2}+\cos\frac{27\pi}{20}\right)$

$$=\prod_{n=0}^{3}\left[\frac{1}{2}+\cos\left(\frac{3^n\pi}{20}\right)\right]$$

គេមាន $\frac{1}{2}+\cos a=\frac{1}{2}+1-2\sin^2\frac{a}{2}=\frac{1}{2}\left(3-4\sin^2\frac{a}{2}\right)$

ហើយ $\sin\frac{3a}{2}=3\sin\frac{a}{2}-4\sin^3\frac{a}{2}=\sin\frac{a}{2}\left(3-4\sin^2\frac{a}{2}\right)$

នាំឱ្យ $3-4\sin^2\frac{a}{2}=\dfrac{\sin\frac{3a}{2}}{\sin\frac{a}{2}}$

ហេតុនេះ $\frac{1}{2}+\cos a=\frac{1}{2}\frac{\sin\frac{3a}{2}}{\sin\frac{a}{2}}$

យក $a=\frac{3^n\pi}{20}$ គេបាន $\frac{1}{2}+\cos\left(\frac{3^n\pi}{20}\right)=\frac{1}{2}.\frac{\sin\frac{3^{n+1}\pi}{40}}{\sin\frac{3^n\pi}{40}}$

គេបាន $P=\prod_{n=0}^{3}\left(\frac{1}{2}.\frac{\sin\frac{3^{n+1}\pi}{40}}{\sin\frac{3^n\pi}{40}}\right)=\frac{1}{16}.\frac{\sin\frac{81\pi}{40}}{\sin\frac{\pi}{40}}=\frac{1}{16}$

ព្រោះ $\sin\frac{81\pi}{40}=\sin(2\pi+\frac{\pi}{40})=\sin\frac{\pi}{40}$ ។

ដូចនេះ

$$(\frac{1}{2}+\cos\frac{\pi}{20})(\frac{1}{2}+\cos\frac{3\pi}{20})(\frac{1}{2}+\cos\frac{9\pi}{20})(\frac{1}{2}+\cos\frac{27\pi}{20})=\frac{1}{16}$$ ។

លំហាត់ទី២៨

ចូរស្រាយថា $\sin^2\frac{\pi}{7}+\sin^2\frac{2\pi}{7}+\sin^2\frac{4\pi}{7}=\frac{7}{4}$

ដំណោះស្រាយ

ស្រាយថា $\sin^2\frac{\pi}{7}+\sin^2\frac{2\pi}{7}+\sin^2\frac{4\pi}{7}=\frac{7}{4}$

តាង $S=\sin^2\frac{\pi}{7}+\sin^2\frac{2\pi}{7}+\sin^2\frac{4\pi}{7}$

យើងបាន $S=\dfrac{1-\cos\frac{2\pi}{7}}{2}+\dfrac{1-\cos\frac{4\pi}{7}}{2}+\dfrac{1-\cos\frac{8\pi}{7}}{2}$

$$=\frac{3}{2}-\frac{1}{2}\left(\cos\frac{2\pi}{7}+\cos\frac{4\pi}{7}+\cos\frac{8\pi}{7}\right)$$

តាង $T=\cos\frac{2\pi}{7}+\cos\frac{4\pi}{7}+\cos\frac{8\pi}{7}$

$$=\cos(\pi-\frac{5\pi}{7})+\cos(\pi-\frac{3\pi}{7})+\cos(\pi+\frac{\pi}{7})$$

$$=-\cos\frac{5\pi}{7}-\cos\frac{3\pi}{7}-\cos\frac{\pi}{7}$$

គុណអង្គទាំងពីរនឹង $2\sin\frac{\pi}{7}$ គេបាន ៖

$$2T\sin\frac{\pi}{7}=-2\cos\frac{5\pi}{7}\sin\frac{\pi}{7}-2\cos\frac{3\pi}{7}\sin\frac{\pi}{7}-2\cos\frac{\pi}{7}\sin\frac{\pi}{7}$$

តាមរូបមន្ត $2\cos a\sin b=\sin(a+b)-\sin(a-b)$

$$2T\sin\frac{\pi}{7}=-2\cos\frac{5\pi}{7}\sin\frac{\pi}{7}-2\cos\frac{3\pi}{7}\sin\frac{\pi}{7}-2\cos\frac{\pi}{7}\sin\frac{\pi}{7}$$

$$2T\sin\frac{\pi}{7}=-(\sin\frac{6\pi}{7}-\sin\frac{4\pi}{7})-(\sin\frac{4\pi}{7}-\sin\frac{2\pi}{7})-\sin\frac{2\pi}{7}$$

$$2T\sin\frac{\pi}{7}=-\sin\frac{6\pi}{7}=-\sin(\pi-\frac{\pi}{7})=-\sin\frac{\pi}{7}$$

គេទាញបាន $T=-\frac{1}{2}$ នាំឲ្យ $S=\frac{3}{2}-\frac{1}{2}(-\frac{1}{2})=\frac{7}{4}$

ដូចនេះ: $\sin^2\frac{\pi}{7}+\sin^2\frac{2\pi}{7}+\sin^2\frac{4\pi}{7}=\frac{7}{4}$ ។

លំហាត់ទី២៩

ចំពោះគ្រប់ចំនួនពិត x ចូរស្រាយបញ្ជាក់ថា ៖

$$\cos^7 x+\cos^7(x+\frac{2\pi}{3})+\cos^7(x+\frac{4\pi}{3})=\frac{63}{64}\cos 3x$$

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

$$\cos^7 x+\cos^7(x+\frac{2\pi}{3})+\cos^7(x+\frac{4\pi}{3})=\frac{63}{64}\cos 3x$$

តាង $E_n(x)=\cos^n x+\cos^n(x+\frac{2\pi}{3})+\cos^n(x+\frac{4\pi}{3})$ (i)

តាមរូបមន្ត $\cos 3x=4\cos^3 x-3\cos x$

គេទាញ $\cos^3 x=\frac{3}{4}\cos x+\frac{1}{4}\cos 3x$

ដោយគុណអង្គទាំងពីរនឹង $\cos^{n-3} x$ គេបាន៖

$$\cos^n x=\frac{3}{4}\cos^{n-2} x+\frac{1}{4}\cos 3x\cos^{n-3} x \quad (1)$$

ដូចគ្នាដែរគេទាញបាន៖

$$\cos^n(x+\frac{2\pi}{3})=\frac{3}{4}\cos^{n-2}(x+\frac{2\pi}{3})+\frac{1}{4}\cos 3x\cos^{n-3}(x+\frac{2\pi}{3})\quad(2)$$

$$\cos^n(x+\frac{4\pi}{3})=\frac{3}{4}\cos^{n-2}(x+\frac{4\pi}{3})+\frac{1}{4}\cos 3x\cos^{n-3}(x+\frac{4\pi}{3})\quad(3)$$

ដោយបូកសមីការ (1); (2) និង (3) គេបាន៖

$$E_n(x)=\frac{3}{4}E_{n-2}(x)+\frac{1}{4}\cos 3x\,E_{n-3}(x)\quad(ii)$$

តាម (i) ចំពោះ $n=0\,;n=1\,,n=2$ គេបាន៖

$$E_0(x)=3$$

$$E_1(x)=\cos x+\cos(x+\frac{2\pi}{3})+\cos(x+\frac{4\pi}{3})$$

$$E_1(x)=\cos x-\frac{1}{2}\cos x-\frac{\sqrt{3}}{2}\sin x-\frac{1}{2}\cos x+\frac{\sqrt{3}}{2}\sin x=0$$

$$E_2(x)=\cos^2 x+(-\frac{1}{2}\cos x-\frac{\sqrt{3}}{2}\sin x)^2+(-\frac{1}{2}\cos x+\frac{\sqrt{3}}{2}\sin x)^2$$

$$E_2(x)=\frac{3}{2}\cos^2 x+\frac{3}{2}\sin^2 x$$

តាម (ii) ចំពោះ $n=3\,;n=4\,,n=5\,;n=7$ គេបាន

$$E_3(x)=\frac{3}{4}E_1(x)+\frac{1}{4}\cos 3x\,E_0(x)=\frac{3}{4}\cos 3x$$

$$E_4(x)=\frac{3}{4}E_2(x)+\frac{1}{4}\cos 3x E_1(x)=\frac{9}{8}$$

$$E_5(x)=\frac{3}{4}E_3(x)+\frac{1}{4}\cos 3x\,E_2(x)=\frac{9}{16}\cos 3x+\frac{3}{8}\cos 3x=\frac{15}{16}\cos 3x$$

$$E_7(x)=\frac{3}{4}E_5(x)+\frac{1}{4}\cos 3x\,E_4(x)=\frac{45}{64}\cos 3x+\frac{9}{32}\cos 3x=\frac{63}{64}\cos 3x$$

ដូចនេះ $\cos^7 x+\cos^7(x+\frac{2\pi}{3})+\cos^7(x+\frac{4\pi}{3})=\frac{63}{64}\cos 3x$ ។

លំហាត់ទី៣០

គណនាផលបូកខាងក្រោម

$$S_n = \frac{\tan\frac{\pi}{8}}{\cos\frac{\pi}{4}} + \frac{\tan\frac{\pi}{16}}{\cos\frac{\pi}{8}} + \frac{\tan\frac{\pi}{32}}{\cos\frac{\pi}{16}} + \dots + \frac{\tan\frac{\pi}{2^n}}{\cos\frac{\pi}{2^{n-1}}}$$

រួចទាញរកលីមីតនៃ S_n កាលណា $n \to +\infty$ ។

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

តាមរូបមន្ត $\tan 2x = \frac{2\tan x}{1-\tan^2 x}$

គេបាន $\tan 2x - \tan x = \frac{2\tan x}{1-\tan^2 x} - \tan x = \frac{\tan x + \tan^2 x}{1-\tan^2 x}$

$$\tan 2x - \tan x = \tan x . \frac{1+\tan^2 x}{1-\tan^2 x}$$

ដោយ $\cos 2x = \frac{1-\tan^2 x}{1+\tan^2 x}$

នោះ $\tan 2x - \tan x = \dfrac{\tan x}{\cos 2x}$ (*)

ដោយជ្រើសរើស $x = \dfrac{\pi}{2^{k+2}}$ ជួសក្នុង (*)

គេបាន $\tan\dfrac{\pi}{2^{k+1}} - \tan\dfrac{\pi}{2^{k+2}} = \dfrac{\tan\dfrac{\pi}{2^{k+2}}}{\cos\dfrac{\pi}{2^{k+1}}}$

$S_n = \sum_{k=1}^{n} ([illegible])$

$= (\tan\frac{\pi}{4} - \tan\frac{\pi}{8}) + (\tan\frac{\pi}{8} - \tan\frac{\pi}{16}) + \dots + ([illegible])$

$= \tan\frac{\pi}{4} - [illegible]$

ដូចនេះ $S_n = 1 - \tan\frac{\pi}{2^{[illegible]}}$ ។

ម្យ៉ាងទៀតគេមាន $\lim\limits_{n \to \infty} \tan\frac{\pi}{[illegible]} = [illegible]$

ដូចនេះ $\lim\limits_{n\to\infty} S_n = [illegible]$ ។

លំហាត់ទី៣១

ក)ចូរស្រាយថា $\frac{\tan^3 x}{1-\tan^2 x}=\frac{1}{2}\tan 2x-\tan x$

ខ)ចូរគណនាផលបូក $S_n=\sum_{k=0}^{n}\left(\frac{2^k \tan^3 \frac{a}{2^n}}{1-\tan^2 \frac{a}{2^n}}\right)$

ដំណោះស្រាយ

ក) ស្រាយថា $\frac{\tan^3 x}{1-\tan^2 x}=\frac{1}{2}\tan 2x-\tan x$

យើងបាន $\frac{1}{2}\tan 2x-\tan x=\frac{\tan x}{1-\tan^2 x}-\tan x=\frac{\tan^3 x}{1-\tan^2 x}$

ដូចនេះ $\frac{\tan^3 x}{1-\tan^2 x}=\frac{1}{2}\tan 2x-\tan x$ ។

ខ)គណនាផលបូក $S_n=\sum_{k=0}^{n}\left(\dfrac{2^k\tan^3\frac{a}{2^k}}{1-\tan^2\frac{a}{2^k}}\right)$

គេមាន $\dfrac{\tan^3 x}{1-\tan^2 x}=\dfrac{1}{2}\tan 2x-\tan x$ យក $x=\dfrac{a}{2^k}$

គេបាន $\dfrac{\tan^3\frac{a}{2^k}}{1-\tan^2\frac{a}{2^k}}=\dfrac{1}{2}\tan\dfrac{a}{2^{k-1}}-\tan\dfrac{a}{2^k}$

យើងបាន៖

$$S_n=\sum_{k=0}^{n}\left(2^{k-1}\tan\frac{a}{2^{k-1}}-2^k\tan\frac{a}{2^k}\right)$$

$$=\frac{1}{2}\tan 2a-2^n\tan\frac{a}{2^n}$$

ដូចនេះ $S_n=\dfrac{1}{2}\tan 2a-2^n\tan\dfrac{a}{2^n}$

លំហាត់ទី៣២

គណនាផលគុណខាងក្រោម ៖

ក) ចូរស្រាយថា $\frac{1}{\sin 2x} = \cot x - \cot 2x$

ខ) ចូរគណនា $S_n = \frac{1}{\sin a} + \frac{1}{\sin \frac{a}{2}} + \frac{1}{\sin \frac{a}{2^2}} + ... + \frac{1}{\sin \frac{a}{2^n}}$

ដំណោះស្រាយ

ក) ស្រាយថា $\frac{1}{\sin 2x} = \cot x - \cot 2x$

តាង $f(x) = \cot x - \cot 2x$

$$= \frac{\cos x}{\sin x} - \frac{\cos 2x}{\sin 2x}$$

$$= \frac{\cos x}{\sin x} - \frac{2\cos^2 x - 1}{2\sin x \cos x}$$

$$= \frac{2\cos^2 x - 2\cos^2 x + 1}{2\sin x \cos x} = \frac{1}{\sin 2x}$$

ដូចនេះ $\frac{1}{\sin 2x} = \cot x - \cot 2x$ ។

ខ)គណនា $S_n = \frac{1}{\sin a} + \frac{1}{\sin \frac{a}{2}} + \frac{1}{\sin \frac{a}{2^2}} + ... + \frac{1}{\sin \frac{a}{2^n}}$

យើងបាន $S_n = \sum_{k=0}^{n} \left(\frac{1}{\sin \frac{a}{2^k}} \right)$

ដោយ $\frac{1}{\sin 2x} = \cot x - \cot 2x$

$$S_n = \sum_{k=0}^{n} \left(\cot \frac{a}{2^{k+1}} - \cot \frac{a}{2^k} \right)$$

$$= \cot \frac{a}{2^{n+1}} - \cot a$$

ដូចនេះ $S_n = \cot \frac{a}{2^{n+1}} - \cot a$ ។

លំហាត់ទី៣៣

ក)ចូរស្រាយបញ្ជាក់ថា $\tan 2x.\tan^2 x = \tan 2x - 2\tan x$

ខ)ចូរគណនាផលបូក $S_n = \sum_{k=0}^{n}\left[2^k \tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}}\right]$

ដំណោះស្រាយ

ក)ស្រាយបញ្ជាក់ថា $\tan 2x.\tan^2 x = \tan 2x - 2\tan x$

តាង $f(x) = \tan 2x - 2\tan x$ ដោយ $\tan 2x = \dfrac{2\tan x}{1-\tan^2 x}$

គេបាន $f(x) = \dfrac{2\tan x}{1-\tan^2 x} - 2\tan x$

$$= \frac{2\tan x - 2\tan x(1-\tan^2 x)}{1-\tan^2 x}$$

$$= \frac{2\tan x - 2\tan x + 2\tan^3 x}{1-\tan^2 x}$$

$$= \frac{2\tan^3 x}{1-\tan^2 x} = \frac{2\tan x}{1-\tan^2 x}.\tan^2 x = \tan 2x.\tan^2 x$$

ដូចនេះ $\tan 2x.\tan^2 x = \tan 2x - 2\tan x$ ។

ខ)គណនាផលបូក $S_n = \sum_{k=0}^{n}\left[2^k \tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}}\right]$

យើងមាន $\tan 2x.\tan^2 x = \tan 2x - 2\tan x$

ដោយយក $x = \frac{a}{2^{k+1}}$

គេបាន $\tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}} = \tan\frac{a}{2^k} - 2\tan\frac{a}{2^{k+1}}$

$$S_n = \sum_{k=0}^{n}\left(2^k\tan\frac{a}{2^k} - 2^{k+1}\tan\frac{a}{2^{k+1}}\right) = \tan a - 2^{n+1}\tan\frac{a}{2^{n+1}}$$

ដូចនេះ

$$S_n = \sum_{k=0}^{n}\left[2^k\tan\frac{a}{2^k}\tan^2\frac{a}{2^{k+1}}\right] = \tan a - 2^{n+1}\tan\frac{a}{2^{n+1}}$$ ។

លំហាត់ទី៣៤

ក)ចូរស្រាយថា $\dfrac{1}{\cos^2 x} = \dfrac{4}{\sin^2 2x} - \dfrac{1}{\sin^2 x}$

ខ)ចូរគណនា $S_n = \dfrac{1}{4\cos^2 \frac{a}{2}} + \dfrac{1}{4^2 \cos \frac{a}{2^2}} + ... + \dfrac{1}{4^n \cos^2 \frac{a}{2^n}}$

ដំណោះស្រាយ

ក)ស្រាយថា $\dfrac{1}{\cos^2 x} = \dfrac{4}{\sin^2 2x} - \dfrac{1}{\sin^2 x}$

យើងមាន

$$\frac{1}{\cos^2 x} + \frac{1}{\sin^2 x} = \frac{\sin^2 x + \cos^2 x}{\sin^2 x \cos^2 x} = \frac{1}{\sin^2 x \cos^2 x} = \frac{4}{\sin^2 2x}$$

ដូចនេះ: $\dfrac{1}{\cos^2 x} = \dfrac{4}{\sin^2 2x} - \dfrac{1}{\sin^2 x}$ ។

ខ) គណនាផលបូក៖

$$S_n=\frac{1}{4\cos^2\frac{a}{2}}+\frac{1}{4^2\cos\frac{a}{2^2}}+....+\frac{1}{4^n\cos^2\frac{a}{2^n}}$$

យើងបាន $S_n=\sum_{k=1}^{n}\left(\frac{1}{4^k}\cdot\frac{1}{\cos^2\frac{a}{2^k}}\right)$

ដោយ $\frac{1}{\cos^2 x}=\frac{4}{\sin^2 2x}-\frac{1}{\sin^2 x}$

គេបាន ៖

$$S_n=\sum_{k=1}^{n}\left[\frac{1}{4^k}\left(\frac{4}{\sin^2\frac{a}{2^{k-1}}}-\frac{1}{\sin^2\frac{a}{2^k}}\right)\right]$$

$$=\sum_{k=1}^{n}\left(\frac{1}{4^{k-1}}\cdot\frac{1}{\sin^2\frac{a}{2^{k-1}}}-\frac{1}{4^k}\cdot\frac{1}{\sin^2\frac{a}{2^k}}\right)=\frac{1}{\sin^2 a}-\frac{1}{4^n\sin^2\frac{a}{2^n}}$$

ដូចនេះ $S_n=\frac{1}{\sin^2 a}-\frac{1}{4^n\sin^2\frac{a}{2^n}}$ ។

លំហាត់ទី៣៥

ក)ចូរស្រាយថា $\dfrac{\tan^3 x}{1-3\tan^2 x} = \dfrac{1}{8}(\tan 3x - 3\tan x)$

ខ)ចូរគណនាផលបូក $S_n = \sum_{k=0}^{n}\left[\dfrac{3^k \tan^3 \frac{a}{3^k}}{1-3\tan^2 \frac{a}{3^k}}\right]$

ដំណោះស្រាយ

ក)ស្រាយថា $\dfrac{\tan^3 x}{1-3\tan^2 x} = \dfrac{1}{8}(\tan 3x - 3\tan x)$

តាមរូបមន្ត $\tan 3x = \dfrac{3\tan x - \tan^3 x}{1-3\tan^2 x}$

យើងបាន $\tan 3x - 3\tan x = \dfrac{3\tan x - \tan^3 x}{1-3\tan^2 x} - 3\tan x = \dfrac{8\tan^3 x}{1-3\tan^2 x}$

ដូចនេះ: $\dfrac{\tan^3 x}{1-3\tan^2 x} = \dfrac{1}{8}(\tan 3x - 3\tan x)$ ។

ខ)គណនាផលបូក $S_n = \sum_{k=0}^{n} \left[\dfrac{3^k \tan^3 \frac{a}{3^k}}{1 - 3\tan^2 \frac{a}{3^k}} \right]$

យើងមាន $\dfrac{\tan^3 x}{1 - 3\tan^2 x} = \dfrac{1}{8}(\tan 3x - 3\tan x)$

ដោយយក $x = \dfrac{a}{3^k}$

គេបាន $\dfrac{\tan^3 \frac{a}{3^k}}{1 - 3\tan^2 \frac{a}{3^k}} = \dfrac{1}{8}\left(\tan \dfrac{a}{3^{k-1}} - 3\tan \dfrac{a}{3^k}\right)$

យើងបាន

$$S_n = \frac{1}{8}\sum_{k=0}^{n}\left(3^k \tan \frac{a}{3^{k-1}} - 3^{k+1}\tan \frac{a}{3^k}\right) = \frac{1}{8}\left(\tan 3a - 3^{n+1}\tan \frac{a}{3^n}\right)$$

ដូចនេះ $S_n = \dfrac{\tan 3a}{8} - \dfrac{3^{n+1}}{8}\tan \dfrac{a}{3^n}$ ។

លំហាត់ទី៣៦

ចំពោះគ្រប់ $n \in IN$ គេឱ្យ $S_n = \cos\frac{n\pi}{12} + \sin\frac{n\pi}{12}$

ក)គណនាតម្លៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$

ខ)បង្ហាញថា [illegible]

ដំណោះស្រាយ

គណនាផលគុណខាងក្រោម ៖

ក. គណនាតម្លៃ $\cos\frac{\pi}{12}$ និង $\sin\frac{\pi}{12}$

ដោយគេមាន $\frac{\pi}{12} = \frac{\pi}{3} - \frac{\pi}{4}$ នោះគេបាន ៖

$$\cos\frac{\pi}{12} = \cos\left(\frac{\pi}{3} - \frac{\pi}{4}\right)$$

$$= \cos\frac{\pi}{3}\cos\frac{\pi}{4} + \sin\frac{\pi}{3}\sin\frac{\pi}{4}$$

$$= \frac{1}{2}\cdot\frac{\sqrt{2}}{2} + \frac{\sqrt{3}}{2}\cdot\frac{\sqrt{2}}{2} = \frac{\sqrt{6}+\sqrt{2}}{4}$$

$$\sin\frac{\pi}{12}=\sin\left(\frac{\pi}{3}-\frac{\pi}{4}\right)$$

$$=\sin\frac{\pi}{3}\cos\frac{\pi}{4}-\sin\frac{\pi}{4}\cos\frac{\pi}{3}$$

$$=\frac{\sqrt{3}}{2}\cdot\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}\cdot\frac{1}{2}=\frac{\sqrt{6}-\sqrt{2}}{4}$$

ដូចនេះ [illegible] ។

ខ)បង្ហាញថា [illegible]

គេមាន [illegible]

តាង [illegible] នោះ [illegible]

គេមាន [illegible]

ហើយ [illegible]

គេបាន x_1 និង x_2 ជាឫសសមីការ $x^2-\frac{\sqrt{6}}{2}x+\frac{1}{4}=0$

ឬ $4x^2 - 2\sqrt{6}x + 1 = 0$

គេទាញ $\begin{cases} 4x_1^2 - 2\sqrt{6}x_1 + 1 = 0 \\ 4x_2^2 - 2\sqrt{6}x_2 + 1 = 0 \end{cases}$

ឬ $\begin{cases} 4x_1^{n+2} - 2\sqrt{6}x_1^{n+1} + x_1^{n} = 0 \quad (i) \\ 4x_2^{n+2} - 2\sqrt{6}x_2^{n+1} + x_2^{n} = 0 \quad (ii) \end{cases}$

បូកសមីការ (i) និង (ii) អង្គនឹងអង្គគេបាន ៖

$$4S_{n+2} - 2\sqrt{6}S_{n+1} + S_n = 0$$

ដូចនេះ $4S_{n+2} = 2\sqrt{6}S_{n+1} - S_n$ ។

លំហាត់ទី៣៧

ក)ចូរស្រាយថា $\frac{\sin(nx)}{\cos^n x}=\left[\frac{\cos(n+1)x}{\cos^{n+1}x}-\frac{\cos(nx)}{\cos^n x}\right].\cot x$

ខ)ចូរគណនា $S_n=\frac{\sin x}{\cos x}+\frac{\sin 2x}{\cos^2 x}+\frac{\sin 3x}{\cos^3 x}+....+\frac{\sin(nx)}{\cos^n x}$

ដំណោះស្រាយ

ក.ស្រាយថា $\frac{\sin(nx)}{\cos^n x}=\left[\frac{\cos(n+1)x}{\cos^{n+1}x}-\frac{\cos(nx)}{\cos^n x}\right].\cot x$

យើងមាន $\cos(n+1)x=\cos(nx+x)$

ឬ $\cos(n+1)x=\cos(nx)\cos x-\sin(nx)\sin x$

ចែកអង្គទាំងពីរនឹង $\cos^{n+1}x$ គេបាន ៖

$$\frac{\cos(n+1)x}{\cos^{n+1}x}=\frac{\cos(nx)\cos x}{\cos^{n+1}x}-\frac{\sin(nx)\sin x}{\cos^{n+1}x}=\frac{\cos(nx)}{\cos^n x}-\frac{\sin(nx)}{\cos^n x}.\tan x$$

នាំឲ្យ $\frac{\sin(nx)}{\cos^n x}=\left[\frac{\cos(n+1)x}{\cos^{n+1}x}-\frac{\cos(nx)}{\cos^n x}\right].\frac{1}{\tan x}$

ដូចនេះ $$\frac{\sin(nx)}{\cos^n x}=\left[\frac{\cos(n+1)x}{\cos^{n+1}x}-\frac{\cos(nx)}{\cos^n x}\right].\cot x$$ ។

ខ.គណនា $$S_n=\frac{\sin x}{\cos x}+\frac{\sin 2x}{\cos^2 x}+\frac{\sin 3x}{\cos^3 x}+....+\frac{\sin(nx)}{\cos^n x}$$

យើងបាន $$S_n=\sum_{k=1}^{n}\left[\frac{\sin(kx)}{\cos^k x}\right]$$

ដោយ $$\frac{\sin(kx)}{\cos^k x}=\left[\frac{\cos(k+1)x}{\cos^{k+1}x}-\frac{\cos(kx)}{\cos^k x}\right].\cot x$$

$$S_n=\cot x\sum_{k=1}^{n}\left(\frac{\cos(k+1)x}{\cos^{k+1}x}-\frac{\cos(kx)}{\cos^k x}\right)=\cot x\left(\frac{\cos(n+1)x}{\cos^{n+1}x}-1\right)$$

ដូចនេះ $$S_n=\frac{\cot x[\cos(n+1)x-\cos^{n+1}x]}{\cos^{n+1}x}$$ ។

លំហាត់ទី៣៨

ក) ចូរស្រាយថា $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$

ខ) គណនា $P_n=(1+\frac{1}{\cos a})(1+\frac{1}{\cos\frac{a}{2}})(1+\frac{1}{\cos\frac{a}{2^2}}).....(1+\frac{1}{\cos\frac{a}{2^n}})$

ដំណោះស្រាយ

ក) ស្រាយថា $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$

យើងតាង $A(x)=1+\frac{1}{\cos x}$

$$=\frac{\cos x+1}{\cos x}=\frac{2\cos^2\frac{x}{2}}{\cos x}=\frac{2\cos^2\frac{x}{2}\sin\frac{x}{2}}{\cos x\sin\frac{x}{2}}=\frac{\cos\frac{x}{2}\sin x}{\cos x\sin\frac{x}{2}}$$

$$=\frac{\cos\frac{x}{2}}{\sin\frac{x}{2}}.\frac{\sin x}{\cos x}=\tan\frac{x}{2}\tan x=\frac{\cot\frac{x}{2}}{\cot x}$$

ដូចនេះ $1+\frac{1}{\cos x}=\frac{\cot\frac{x}{2}}{\cot x}$ ។

ខ)គណនាផលគុណ

$$P_n=(1+\frac{1}{\cos a})(1+\frac{1}{\cos\frac{a}{2}})(1+\frac{1}{\cos\frac{a}{2^2}}).....(1+\frac{1}{\cos\frac{a}{2^n}})$$

$$=\prod_{k=0}^{n}\left(1+\frac{1}{\cos\frac{a}{2^k}}\right)=\prod_{k=0}^{n}[\frac{\cot\frac{a}{2^{k+1}}}{\cot\frac{a}{2^k}}]$$

ដូចនេះ $P_n=\tan\frac{a}{2^{n+1}}.\cot a$ ។

លំហាត់ទី៣៩

គណនាផលគុណខាងក្រោមនេះ

$$P_n = \prod_{k=1}^{n}\left[\frac{1+\tan^2 2^k x}{\left(1-\tan^2 2^k\right)^2}\right] \quad \text{ដែល } |x| < \frac{\pi}{2^{n+2}}$$

ដំណោះស្រាយ

តាមរូបមន្ត $\cos 2a = \dfrac{1-\tan^2 a}{1+\tan^2 a}$

គេបាន $\cos 2^{k+1}x = \dfrac{1-\tan^2 2^k x}{1+\tan^2 2^k x}$

ហើយ $1-\tan^2 2^k = \dfrac{\cos^2 2^k - \sin^2 2^k}{\cos^2 2^k x} = \dfrac{\cos 2^{k+1}x}{\cos^2 2^k x}$

គេបាន $\dfrac{1+\tan^2 2^k x}{(1-\tan^2 2^k x)^2} = \dfrac{\cos^2 2^k x}{\cos^2 2^{k+1}x}$

ដូចនេះ $P_n = \prod_{k=1}^{n}\left(\dfrac{\cos^2 2^k x}{\cos^2 2^{k+1}x}\right) = \dfrac{\cos^2 2x}{\cos^2 2^{n+1}x}$ ។

លំហាត់ទី៤០

គណនាផលគុណខាងក្រោម៖

$$P_n = \prod_{k=0}^{n}\left[(1-\tan^2\frac{x}{2^k})^{2^k}\right]$$

ដំណោះស្រាយ

គណនាផលគុណ $P_n = \prod_{k=0}^{n}\left[(1-\tan^2\frac{x}{2^k})^{2^k}\right]$

យើងមាន $1-\tan^2\frac{x}{2^k} = \dfrac{\cos^2\frac{x}{2^k} - \sin^2\frac{x}{2^k}}{\cos^2\frac{x}{2^k}} = \dfrac{\cos\frac{2x}{2^k}}{\cos^2\frac{x}{2^k}}$

គេបាន $P_n = \prod_{k=0}^{n}\left[\dfrac{\cos^{2^k}\frac{x}{2^{k-1}}}{\cos^{2^{k+1}}\frac{x}{2^k}}\right] = \dfrac{\cos 2x}{\cos^{2^{n+1}}\frac{x}{2^n}}$

ដូចនេះ៖ $P_n = \dfrac{\cos 2x}{\cos^{2^{n+1}}\frac{x}{2^n}}$ ។

លំហាត់ទី៤១

គណនាផលគុណខាងក្រោម៖

$$P_n = \prod_{k=0}^{n}\left(\tan^{2^k}\frac{x}{2^k}\right) = \tan x . \tan^2\frac{x}{2} . \tan^4\frac{x}{4} ..... \tan^{2^n}\frac{x}{2^n}$$

ដំណោះស្រាយ

គេមាន $\tan a = \dfrac{\sin a}{\cos a} = \dfrac{2\sin^2 a}{2\sin a\cos a} = \dfrac{2\sin^2 a}{\sin 2a}$

យក $a = \dfrac{x}{2^k}$ គេបាន $\tan\dfrac{x}{2^k} = \dfrac{2\sin^2\dfrac{x}{2^k}}{\sin\dfrac{2x}{2^k}}$

គេទាញ $P_n = \displaystyle\prod_{k=0}^{n}\left(2^{2^k} . \frac{\sin^{2^{k+1}}\dfrac{x}{2^k}}{\sin^{2^k}\dfrac{2x}{2^k}}\right) = 2^{2^{n+1}-1} . \frac{\sin^{2^{n+1}}\dfrac{x}{2^n}}{\sin 2x}$

ដូចនេះ $P_n = 2^{(2^{n+1}-1)} . \dfrac{\sin^{2^{n+1}}\dfrac{x}{2^n}}{\sin 2x}$ ។

លំហាត់ទី៤២

ចូរគណនាតម្លៃផលគុណ៖

$$P=(\sqrt{3}+\tan 1^{o})(\sqrt{3}+\tan 2^{o}).....(\sqrt{3}+\tan 29^{o})$$

ដំណោះស្រាយ

គណនាតម្លៃផលគុណ $P=\prod_{k=1}^{29}\left(\sqrt{3}+\tan k^{o}\right)$

គេមាន $\sqrt{3}+\tan k^{o}=\sqrt{3}+\dfrac{\sin k^{o}}{\cos k^{o}}=\dfrac{\sqrt{3}\cos k^{o}+\sin k^{o}}{\cos k^{o}}$

$$=\frac{2\cos(30^{o}-k^{o})}{\cos k^{o}}$$

គេបាន $P=\prod_{k=1}^{29}\left[\dfrac{2\cos(30^{o}-k^{o})}{\cos k^{o}}\right]$

$$=\frac{2^{29}\cos 29^{o}\cos 28^{o}.....\cos 2^{o}\cos 1^{o}}{\cos 1^{o}\cos 2^{o}.....\cos 28^{o}\cos 29^{o}}=2^{29}$$

ដូចនេះ $(\sqrt{3}+\tan 1^{o})(\sqrt{3}+\tan 2^{o}).....(\sqrt{3}+\tan 29^{o})=2^{29}$

លំហាត់ទី៤៣

គណនាតម្លៃនៃផលគុណ

$$P=(1-\cot 1^o)(1-\cot 2^o)(1-\cot 3^o).....(1-\cot 44^o)$$

ដំណោះស្រាយ

យើងពិនិត្យ $1-\cot a=1-\dfrac{\cos a}{\sin a}=\dfrac{\sin a-\cos a}{\sin a}$

ដោយ $\sin a-\cos a=\sqrt{2}\sin(45^o-a)$

ហេតុនេះ $1-\cot a=\sqrt{2}\dfrac{\sin(45^o-a)}{\sin a}$

យើងបាន $P=\prod_{a=1^o}^{44^o}(1-\cot a)=\prod_{a=1^o}^{44^o}\left[\sqrt{2}\dfrac{\sin(45^o-a)}{\sin a}\right]$

$$P=(\sqrt{2})^{44}\frac{\sin 44^o.\sin 43^o.....\sin 1^o}{\sin 1^o.\sin 2^o.....\sin 44^o}=2^{22}$$

ដូចនេះ $P=(1-\cot 1^o)(1-\cot 2^o).....(1-\cot 44^o)=2^{22}$ ។

លំហាត់ទី៤៤

គណនា $A=\cos\frac{\pi}{11}+\cos\frac{3\pi}{11}+\cos\frac{5\pi}{11}+\cos\frac{7\pi}{11}+\cos\frac{9\pi}{11}$

ដំណោះស្រាយ

យក $z=\cos\frac{\pi}{11}+i.\sin\frac{\pi}{11}$ ហើយ $z^{11}=-1$

$$W=z+z^3+z^5+z^7+z^9=\frac{z^{11}-z}{z^2-1}=\frac{-1-z}{z^2-1}=\frac{1}{1-z}$$

ដោយ $1-z=1-\cos\frac{\pi}{11}-i\sin\frac{\pi}{11}=2\sin\frac{\pi}{22}(\sin\frac{\pi}{22}-i\cos\frac{\pi}{22})$

$$W=\frac{1}{2\sin\frac{\pi}{22}(\sin\frac{\pi}{22}-i\cos\frac{\pi}{22})}=\frac{1}{2}+i\frac{1}{2}\cot\frac{\pi}{22}$$

ផ្នែកពិតនៃ W គឺ $\cos\frac{\pi}{11}+\cos\frac{3\pi}{11}+\cos\frac{5\pi}{11}+\cos\frac{7\pi}{11}+\cos\frac{9\pi}{11}$

ដូចនេះ

$$A=\cos\frac{\pi}{11}+\cos\frac{3\pi}{11}+\cos\frac{5\pi}{11}+\cos\frac{7\pi}{11}+\cos\frac{9\pi}{11}=\frac{1}{2}$$

លំហាត់ទី៤៥

គណនា $P = \cos 20^o \cos 40^o \cos 80^o$

ដំណោះស្រាយ

គណនា $P = \cos 20^o \cos 40^o \cos 80^o$

តាង $z = \cos 20^o + i \sin 20^o$ ហើយ $z^9 = \cos 180^o + i \sin 180^o = -1$

$$\cos 20^o = \frac{z + \overline{z}}{2} = \frac{z + \frac{1}{z}}{2} = \frac{z^2 + 1}{2z}$$ (ព្រោះ $\overline{z} = \frac{1}{z}$)

$$\cos 40^o = \frac{z^2 + \overline{z}^2}{2} = \frac{z^4 + 1}{2z^2} \; ; \; \cos 80^o = \frac{z^4 + \overline{z}^4}{2} = \frac{z^8 + 1}{2z^4}$$

$$P = \frac{(z^2+1)(z^4+1)(z^8+1)}{8z^7} = \frac{(z^2-1)(z^2+1)(z^4+1)(z^8+1)}{8z^7(z^2-1)}$$

$$= \frac{z^{16} - 1}{8(z^9 - z^7)} = \frac{-z^7 - 1}{8(-1 - z^7)} = \frac{1}{8}$$

ដូចនេះ $P = \cos 20^o \cos 40^o \cos 80^o = \frac{1}{8}$ ។

លំហាត់ទី៤៦

គេឱ្យ $a ; b ; c ; d$ និង x ជាចំនួនពិតផ្ទៀងផ្ទាត់៖

$$\frac{\sin x}{a}=\frac{\sin 2x}{b}=\frac{\sin 3x}{c}=\frac{\sin 4x}{d}$$ ដែល $x \neq k\pi \; ; \; k \in \mathbb{Z}$

ចូរបង្ហាញថា $a^3(4b^2-d^2)=b^4(3a-c)$

ដំណោះស្រាយ

តាង $\frac{\sin x}{a}=\frac{\sin 2x}{b}=\frac{\sin 3x}{c}=\frac{\sin 4x}{d}=t$

គេទាញ $\begin{cases}\sin x = at\\ \sin 2x = bt\\ \sin 3x = ct\\ \sin 4x = dt\end{cases}$

គេមាន $\sin 4x = 2\sin 2x\cos 2x$

$$\sin^2 4x = 4\sin^2 2x\cos^2 2x$$

$$\sin^2 4x = 4\sin^2 2x(1-\sin^2 2x)$$

$$d^2t^2 = 4b^2t^2(1-b^2t^2)$$

គេទាញ $t^2 = \frac{1}{b^2}\left(1 - \frac{d^2}{4b^2}\right)$ (1)

ម៉្យាងទៀត $\sin 3x = 3\sin x - 4\sin^3 x$

$$\sin 3x = \sin x(3 - 4\sin^2 x)$$

$$ct = at(3 - 4a^2t^2)$$

គេទាញ $t^2 = \frac{1}{4a^2}(3 - \frac{c}{a})$ (2)

ផ្ទឹម (1) និង (2) គេបាន

$$\frac{1}{b^2}\left(1 - \frac{d^2}{4b^2}\right) = \frac{1}{4a^2}\left(3 - \frac{c}{a}\right)$$

$$\frac{4b^2 - d^2}{4b^4} = \frac{3a - c}{4a^3}$$

គុណអង្គទាំងពីរនឹង a^3b^4 គេបាន $a^3(4b^2 - d^2) = b^4(3a - c)$

ដូចនេះ $a^3(4b^2 - d^2) = b^4(3a - c)$ ។

លំហាត់ទី៤៧

គេឱ្យ a, b, c, d ជាចំនួននៅក្នុងចន្លោះ $[0;\pi]$ ដោយដឹងថា

[illegible]

ចូរបង្ហាញថា $2\cos(a-d)=7\cos(b-c)$ ។

ដំណោះស្រាយ

គេមាន [illegible]

ឬ [illegible]

ឬ [illegible]

បូកសមីការ (i) និង (ii) អង្គនឹងអង្គគេបាន ៖

[illegible]

ដូចនេះ $2\cos(a-d)=7\cos(b-c)$ ។

លំហាត់ទី៤៨

គណនាផលគុណខាងក្រោម ៖

$$P=\tan\frac{\pi}{27}\tan\frac{6\pi}{27}\tan\frac{8\pi}{27}\tan\frac{10\pi}{27}\tan\frac{12\pi}{27}$$

ដំណោះស្រាយ

គណនាផលគុណ $P=\tan\frac{\pi}{27}\tan\frac{6\pi}{27}\tan\frac{8\pi}{27}\tan\frac{10\pi}{27}\tan\frac{12\pi}{27}$

គេមាន $\tan\frac{8\pi}{27}=\tan(\frac{\pi}{3}-\frac{\pi}{27})=\dfrac{\sqrt{3}-\tan\frac{\pi}{27}}{1+\sqrt{3}\tan\frac{\pi}{27}}$

$$\tan\frac{10\pi}{27}=\tan(\frac{\pi}{3}+\frac{\pi}{27})=\frac{\sqrt{3}+\tan\frac{\pi}{27}}{1-\sqrt{3}\tan\frac{\pi}{27}}$$

គេទាញ $\tan\frac{\pi}{27}\tan\frac{8\pi}{27}\tan\frac{10\pi}{27}=\dfrac{3\tan\frac{\pi}{27}-\tan^3\frac{\pi}{27}}{1-3\tan^2\frac{\pi}{27}}=\tan\frac{\pi}{9}$

គេបាន $P=\tan\frac{\pi}{9}\tan\frac{2\pi}{9}\tan\frac{4\pi}{9}$

គេមាន $\tan\frac{2\pi}{9}=\tan(\frac{\pi}{3}-\frac{\pi}{9})=\frac{\sqrt{3}-\tan\frac{\pi}{9}}{1+\sqrt{3}\tan\frac{\pi}{9}}$

$$\tan\frac{4\pi}{9}=\tan(\frac{\pi}{3}+\frac{\pi}{9})=\frac{\sqrt{3}+\tan\frac{\pi}{9}}{1-\sqrt{3}\tan\frac{\pi}{9}}$$

គេទាញ $\tan\frac{2\pi}{9}\tan\frac{4\pi}{9}=\frac{3-\tan^2\frac{\pi}{9}}{1-3\tan^2\frac{\pi}{9}}$

គេបាន $P=\frac{3\tan\frac{\pi}{9}-\tan^3\frac{\pi}{9}}{1-3\tan^2\frac{\pi}{9}}=\tan\frac{\pi}{3}=\sqrt{3}$

ដូចនេះ $P=\tan\frac{[illegible]\pi}{27}\tan\frac{6[illegible]}{27}\tan\frac{[illegible]}{27}\tan\frac{1[illegible]}{27}\tan\frac{12[illegible]}{2[illegible]}=\sqrt{3}$

102

TRIGONOMETRY

PROBLEMS

លំហាត់ទី៤៩

ចូរស្រាយបញ្ជាក់ថា ៖

$$\tan\frac{\pi}{30}\tan\frac{7\pi}{30}\tan\frac{11\pi}{30}=\sqrt{1-\frac{2}{\sqrt{5}}}$$

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\tan\frac{\pi}{30}\tan\frac{7\pi}{30}\tan\frac{11\pi}{30}=\sqrt{1-\frac{2}{\sqrt{5}}}$

គេមាន $\tan\frac{7\pi}{30}=\tan(\frac{\pi}{3}-\frac{\pi}{30})=\dfrac{\sqrt{3}-\tan\frac{\pi}{30}}{1+\sqrt{3}\tan\frac{\pi}{30}}$

ហើយ $\tan\frac{11\pi}{30}=\tan(\frac{\pi}{3}+\frac{\pi}{30})=\dfrac{\sqrt{3}+\tan\frac{\pi}{30}}{1-\sqrt{3}\tan\frac{\pi}{30}}$

គេបាន $\tan\frac{\pi}{30}\tan\frac{7\pi}{30}\tan\frac{11\pi}{30}=\dfrac{3\tan\frac{\pi}{30}-\tan^3\frac{\pi}{30}}{1-3\tan^2\frac{\pi}{30}}=\tan\frac{\pi}{10}$

គេមាន $\frac{2\pi}{5}=\pi-\frac{3\pi}{5}$ នោះ $\tan\frac{2\pi}{5}=\tan(\pi-\frac{3\pi}{5})=-\tan\frac{3\pi}{5}$

ដោយ $\tan\frac{2\pi}{5}=\frac{2\tan\frac{\pi}{5}}{1-\tan^2\frac{\pi}{5}}$ និង $\tan\frac{3\pi}{5}=\frac{3\tan\frac{\pi}{5}-\tan^3\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$

គេបាន $\frac{2\tan\frac{\pi}{5}}{1-\tan^2\frac{\pi}{5}}=-\frac{3\tan\frac{\pi}{5}-\tan^3\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$

ឬ $\frac{2}{1-\tan^2\frac{\pi}{5}}=-\frac{3-\tan^2\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$ តាងដ $t=\tan^2\frac{\pi}{5}$

ដោយ $\frac{\pi}{6}<\frac{\pi}{5}<\frac{\pi}{4}$ នោះ $\frac{1}{3}<t<1$

គេបាន $\frac{2}{1-t}=-\frac{3-t}{1-3t}$ នាំឲ្យ $t^2-10t+5=0$

$\Delta'=25-5=20$ គេទាញឫស $t_1=5-2\sqrt{5}\ ,\ t_2=5+2\sqrt{5}$

ដោយ $\frac{1}{3}<t<1$ នោះ $t=5-2\sqrt{5}$

គេបាន $\tan^2\frac{\pi}{5}=5-2\sqrt{5}$ នោះ $\tan\frac{\pi}{5}=\sqrt{5-2\sqrt{5}}$

តាមរូបមន្ត $\tan 2a = \dfrac{2\tan a}{1-\tan^2 a}$

គេបាន $\tan\dfrac{\pi}{5} = \dfrac{2\tan\frac{\pi}{10}}{1-\tan^2\frac{\pi}{10}} = \sqrt{5-2\sqrt{5}}$ តាង $u=\tan\dfrac{\pi}{10}>0$

គេបាន $\dfrac{2u}{1-u^2} = \sqrt{5-2\sqrt{5}}$ ឬ $u^2+\dfrac{2}{\sqrt{5-2\sqrt{5}}}u-1=0$

$$\Delta' = \frac{1}{5-2\sqrt{5}}+1 = \frac{6-2\sqrt{5}}{5-2\sqrt{5}} = \frac{(\sqrt{5}-1)^2}{5-2\sqrt{5}}$$

គេទាញ $\left[\begin{array}{l} t_1 = -\dfrac{1}{\sqrt{5-2\sqrt{5}}}-\dfrac{\sqrt{5}-1}{\sqrt{5-2\sqrt{5}}} = -\dfrac{\sqrt{5}}{\sqrt{5-2\sqrt{5}}} \\ t_2 = -\dfrac{1}{\sqrt{5-2\sqrt{5}}}+\dfrac{\sqrt{5}-1}{\sqrt{5-2\sqrt{5}}} = \dfrac{\sqrt{5}-2}{\sqrt{5-2\sqrt{5}}} = \sqrt{1-\dfrac{2}{\sqrt{5}}} \end{array}\right.$

ដោយ $t>0$ នោះ $\tan\dfrac{\pi}{10} = \sqrt{1-\dfrac{2}{\sqrt{5}}}$

ដូច្នេះ $\tan\dfrac{\pi}{30}\tan\dfrac{7\pi}{30}\tan\dfrac{11\pi}{30} = \sqrt{1-\dfrac{2}{\sqrt{5}}}$

លំហាត់ទី៥០

ចូរស្រាយថា $\cos^3\frac{\pi}{9}-\cos^3\frac{4\pi}{9}+\cos^3\frac{7\pi}{9}=\frac{3}{8}$

ដំណោះស្រាយ

តាង $S=\cos^3\frac{\pi}{9}-\cos^3\frac{4\pi}{9}+\cos^3\frac{7\pi}{9}$

តាមរូបមន្ត $\cos 3a = 4\cos^3 a - 3\cos a$

ឬ $\cos^3 a = \frac{3}{4}\cos a + \frac{1}{4}\cos 3a$

កន្សោមដែលឲ្យអាចសរសេរជា ៖

$$S=\frac{3}{4}(\cos\frac{\pi}{9}-\cos\frac{4\pi}{9}+\cos\frac{7\pi}{9})+\frac{1}{4}(\cos\frac{\pi}{3}-\cos\frac{4\pi}{3}+\cos\frac{7\pi}{3})$$

តាង $A=\cos\frac{\pi}{3}-\cos\frac{4\pi}{3}+\cos\frac{7\pi}{3}=\frac{1}{2}+\frac{1}{2}+\frac{1}{2}=\frac{3}{2}$

ហើយ $B=\cos\frac{\pi}{9}-\cos\frac{4\pi}{9}+\cos\frac{7\pi}{9}$

ដោយ $-\cos\frac{4\pi}{9}=\cos\frac{13\pi}{9}$

$$B=\cos\frac{\pi}{9}+\cos\frac{7\pi}{9}+\cos\frac{13\pi}{9}$$

គុណនឹង $2\sin\frac{\pi}{3}$ គេបាន

$$2B.\sin\frac{\pi}{3}=2\cos\frac{\pi}{9}\sin\frac{\pi}{3}+2\cos\frac{7\pi}{9}\sin\frac{\pi}{3}+2\cos\frac{13\pi}{9}\sin\frac{\pi}{3}$$

$$2\,B.\frac{\sqrt{3}}{2}=\sin\frac{4\pi}{9}-\sin(-\frac{2\pi}{9})+\sin\frac{10\pi}{9}-\sin\frac{4\pi}{9}+\sin\frac{16\pi}{9}-\sin\frac{10\pi}{9}$$

$$B\sqrt{3}=\sin\frac{2\pi}{9}+\sin\frac{16\pi}{9}=2\sin\pi\cos(-\frac{7\pi}{9})=0$$

គេទាញបាន $B=0$

គេបាន $S=\frac{3}{4}B+\frac{1}{4}A=0+\frac{3}{8}=\frac{3}{8}$ ។

ដូចនេះ: $\cos^3\frac{\pi}{9}+\cos^3\frac{4\pi}{9}+\cos^3\frac{7\pi}{9}=\frac{3}{8}$ ។

លំហាត់ទី៥១

ចូរស្រាយថា $\sin\frac{2\pi}{7}+\sin\frac{4\pi}{7}+\sin\frac{8\pi}{7}=\frac{\sqrt{7}}{2}$

ដំណោះស្រាយ

តាង $S=\sin\frac{2\pi}{7}+\sin\frac{4\pi}{7}+\sin\frac{8\pi}{7}$

គេមាន $\sin\frac{2\pi}{7}=\sin\frac{5\pi}{7}$, $\sin\frac{4\pi}{7}=\sin\frac{3\pi}{7}$, $\sin\frac{8\pi}{7}=-\sin\frac{\pi}{7}$

ហើយ $\sin\frac{2\pi}{7}>\sin\frac{\pi}{7}=-\sin\frac{8\pi}{7}$ និង $\sin\frac{4\pi}{7}>0$

គេបាន $S=\sin\frac{5\pi}{7}+\sin\frac{3\pi}{7}-\sin\frac{\pi}{7}>0$

លើកអង្គទាំពីរជាការេគេបាន ៖

$$S^2=\sin^2\frac{5\pi}{7}+\sin^2\frac{3\pi}{7}+\sin^2\frac{\pi}{7}+2\sin\frac{5\pi}{7}\sin\frac{3\pi}{7}-2\sin\frac{5\pi}{7}\sin\frac{\pi}{7}-2\sin\frac{3\pi}{7}\sin\frac{\pi}{7}$$

តាង $A=\sin^2\frac{5\pi}{7}+\sin^2\frac{3\pi}{7}+\sin^2\frac{\pi}{7}$

$$= \frac{3}{2} - \frac{\cos\frac{10\pi}{7} + \cos\frac{6\pi}{7} + \cos\frac{2\pi}{7}}{2}$$

$$= \frac{3}{2} - \frac{1}{2}\left[\ \cos(\pi + \frac{3\pi}{7}) + \cos(\pi - \frac{\pi}{7}) + \cos(\pi - \frac{5\pi}{7})\ \right]$$

$$= \frac{3}{2} - \frac{1}{2}\left(-\cos\frac{3\pi}{7} - \cos\frac{\pi}{7} - \cos\frac{5\pi}{7}\right)$$

យក $B = -\cos\frac{5\pi}{7} - \cos\frac{3\pi}{7} - \cos\frac{\pi}{7}$

គុណអង្គទាំងពីរនឹង $2\sin\frac{\pi}{7}$ គេបាន៖

$$2B\sin\frac{\pi}{7} = -2\cos\frac{5\pi}{7}\sin\frac{\pi}{7} - 2\cos\frac{3\pi}{7}\sin\frac{\pi}{7} - 2\cos\frac{\pi}{7}\sin\frac{\pi}{7}$$

តាមរូបមន្ត $2\cos a\sin b = \sin(a+b) - \sin(a-b)$

$$2B\sin\frac{\pi}{7} = -2\cos\frac{5\pi}{7}\sin\frac{\pi}{7} - 2\cos\frac{3\pi}{7}\sin\frac{\pi}{7} - 2\cos\frac{\pi}{7}\sin\frac{\pi}{7}$$

$$2B\sin\frac{\pi}{7} = -(\ \sin\frac{6\pi}{7} - \sin\frac{4\pi}{7}) - (\sin\frac{4\pi}{7} - \sin\frac{2\pi}{7}) - \sin\frac{2\pi}{7}$$

$2B\sin\frac{\pi}{7} = -\sin$ [illegible] $\sin$ [illegible]

គេទាញ $B = -\frac{1}{2}$ នាំឲ្យ $A = \frac{3}{2} + \frac{1}{4} = \frac{7}{4}$

តាង $C = 2\sin\frac{5\pi}{7}\sin\frac{3\pi}{7} - 2\sin\frac{5\pi}{7}\sin\frac{\pi}{7} - 2\sin\frac{3\pi}{7}\sin\frac{\pi}{7}$

$$= \cos\frac{2\pi}{7} - \cos\frac{8\pi}{7} - \cos\frac{4\pi}{7} + \cos\frac{6\pi}{7} - \cos\frac{2\pi}{7} + \cos\frac{4\pi}{7}$$

$$= \cos\frac{6\pi}{7} - \cos\frac{8\pi}{7} = -2\sin\pi.\sin(-\frac{\pi}{7}) = 0$$

គេបាន $S^2 = A + C = \frac{7}{4} + 0 = \frac{7}{4}$ ដោយ $S > 0$

នោះ $S = \frac{\sqrt{7}}{2}$ ។

ដូចនេះ $\sin\frac{2\pi}{7} + \sin\frac{4\pi}{7} + \sin\frac{8\pi}{7} = \frac{\sqrt{7}}{2}$ ។

លំហាត់ទី៥២

ចូរកំនត់គ្រប់តម្លៃ x ក្នុងចន្លោះ $(0;\frac{\pi}{2})$ ដោយដឹងថា ៖

$$\frac{\sqrt{3}-1}{\sin x}+\frac{\sqrt{3}+1}{\cos x}=4\sqrt{2}$$

ដំណោះស្រាយ

កំនត់គ្រប់តម្លៃ x ក្នុងចន្លោះ $(0;\frac{\pi}{2})$

$$\frac{\sqrt{3}-1}{\sin x}+\frac{\sqrt{3}+1}{\cos x}=4\sqrt{2} \quad (1)$$

គេពិនិត្យ $\sin\frac{\pi}{12}=\sin\left(\frac{\pi}{3}-\frac{\pi}{4}\right)$

$$=\sin\frac{\pi}{3}\cos\frac{\pi}{4}-\sin\frac{\pi}{4}\cos\frac{\pi}{3}$$

$$=\frac{\sqrt{3}}{2}\cdot\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}\cdot\frac{1}{2}=\frac{\sqrt{6}-\sqrt{2}}{4}$$

ហើយ $\cos\frac{\pi}{12}=\cos\left(\frac{\pi}{3}-\frac{\pi}{4}\right)$

$$= \cos\frac{\pi}{3}\cos\frac{\pi}{4} + \sin\frac{\pi}{3}\sin\frac{\pi}{2}$$

$$= \frac{1}{2}.\frac{\sqrt{2}}{2} + \frac{\sqrt{3}}{2}.\frac{\sqrt{2}}{2} = \frac{\sqrt{6}+\sqrt{2}}{4}$$

សមីការ (1) អាចសរសេរទៅជា ៖

$$\frac{\frac{\sqrt{3}-1}{2\sqrt{2}}}{\sin x} + \frac{\frac{\sqrt{3}+1}{2\sqrt{2}}}{\cos x} = 2$$

$$\frac{\frac{\sqrt{6}-\sqrt{2}}{4}}{\sin x} + \frac{\frac{\sqrt{6}+\sqrt{2}}{4}}{\cos x} = 2$$

$$\frac{\sin\frac{\pi}{12}}{\sin x} + \frac{\cos\frac{\pi}{12}}{\cos x} = 2$$

$$\sin\frac{\pi}{12}\cos x + \sin x\cos\frac{\pi}{12} = 2\sin x\cos x$$

$$\sin\left(\frac{\pi}{12} + x\right) = \sin 2x$$

ដោយ $0 < x < \frac{\pi}{2}$ នោះគេទាញ $x = \frac{\pi}{12}$ ឬ $x = \frac{11\pi}{36}$

ដូចនេះ $x \in \{ \frac{\pi}{12} \ ; \ \frac{11\pi}{36} \}$ ។

លំហាត់ទី៥៣

គេឲ្យ $a_0=\sqrt{2}+\sqrt{3}+\sqrt{6}$ និង $a_{n+1}=\dfrac{a_n^{\ 2}-5}{2(a_n+2)}$ គ្រប់ $n\geq 0$

ចូរស្រាយថា $a_n=\cot\left(\dfrac{2^{n-3}\pi}{3}\right)-2$ ចំពោះគ្រប់ $n\in IN$

ដំណោះស្រាយ

ស្រាយថា $a_n=\cot\left(\dfrac{2^{n-3}\pi}{3}\right)-2$

ចំពោះ $n=0$ គេបាន $a_0=\cot\dfrac{\pi}{24}-2$

$$\cot\frac{\pi}{24}=\frac{\cos\frac{\pi}{24}}{\sin\frac{\pi}{24}}=\frac{2\cos^2\frac{\pi}{24}}{2\sin\frac{\pi}{24}\cos\frac{\pi}{24}}=\frac{1+\cos\frac{\pi}{12}}{\sin\frac{\pi}{12}}$$

$$=\frac{1+\cos(\frac{\pi}{3}-\frac{\pi}{4})}{\sin(\frac{\pi}{3}-\frac{\pi}{4})}=\frac{1+\frac{\sqrt{6}+\sqrt{2}}{4}}{\frac{\sqrt{6}-\sqrt{2}}{4}}=\frac{4+\sqrt{6}+\sqrt{2}}{\sqrt{6}-\sqrt{2}}$$

$$\cot\frac{\pi}{24}=\frac{4(\sqrt{6}+\sqrt{2})+(\sqrt{6}+\sqrt{2})^2}{4}$$

$$=\frac{4(\sqrt{6}+\sqrt{2})+8+4\sqrt{3}}{4}$$

$$=2+\sqrt{2}+\sqrt{3}+\sqrt{6}$$

គេទាញ $a_0=\sqrt{2}+\sqrt{3}+\sqrt{6}$

ហេតុនេះ $a_n=\cot\left(\frac{2^{n-3}\pi}{3}\right)-2$ ពិតចំពោះ $n=0$ ។

សន្មតថាវាពិតដល់តួទី k គឺ $a_k=\cot\left(\frac{2^{k-3}\pi}{3}\right)-2$ ពិត

យើងនឹងស្រាយថាវាពិតដល់តួទី $k+1$ គឺ ៖

$a_{k+1}=\cot\left(\frac{2^{k-2}\pi}{3}\right)-2$ ពិត

យើងមាន $a_{k+1}=\frac{a_k{}^2-5}{2(a_k+2)}$

ដោយ $a_k=\cot\left(\frac{2^{k-3}\pi}{3}\right)-2$

នោះ $a_{k+1}=\dfrac{\left[\cot\left(\dfrac{2^{k-3}\pi}{3}\right)-2\right]^2-5}{2\cot\left(\dfrac{2^{k-3}\pi}{3}\right)}$

$$a_{k+1}=\frac{\cot^2\left(\dfrac{2^{k-3}\pi}{3}\right)-4\cot\left(\dfrac{2^{k-3}\pi}{3}\right)-1}{2\cot\left(\dfrac{2^{k-3}\pi}{3}\right)}$$

$$=\frac{\cot^2\left(\dfrac{2^{k-3}\pi}{3}\right)-1}{2\cot\left(\dfrac{2^{k-3}\pi}{2}\right)}-2$$

ដោយប្រើរូបមន្ត $\cot 2a=\dfrac{\cot^2 a-1}{2\cot a}$

គេបាន $a_{k+1}=\cot\left(\dfrac{2^{k-2}\pi}{3}\right)-2$ ពិត ។

ដូចនេះ: $a_n=\cot\left(\dfrac{2^{n-3}\pi}{3}\right)-2$ ។

លំហាត់ទី៥៤

គេឲ្យស្វ៊ីតនៃចំនួនពិត (t_n) កំណត់ដោយ ៖

$t_1 = \sqrt{5-2\sqrt{5}}$ និង $t_{n+1} = \dfrac{3t_n - t_n^3}{1-3t_n^2}$ ដែល $n \in IN$

ក) ចូរស្រាយថា $t_1 = \tan\dfrac{\pi}{5}$ ។

ខ) គេតាង $t_n = \tan u_n$ ដែល $0 < u_n < \dfrac{\pi}{2}$ គ្រប់ $n \in IN$ ។

ចូរស្រាយថា (u_n) ជាស្វ៊ីតធរណីមាត្រមួយ ។

គ)គណនា u_n និង t_n ជាអនុគមន៍នៃ n ។

ដំណោះស្រាយ

ក) ស្រាយថា $t_1 = \tan\dfrac{\pi}{5}$

គេមាន $\dfrac{2\pi}{5} = \pi - \dfrac{3\pi}{5}$

នោះ $\tan\dfrac{2\pi}{5} = \tan(\pi - \dfrac{3\pi}{5}) = -\tan\dfrac{3\pi}{5}$

ដោយ $\tan\frac{2\pi}{5}=\frac{2\tan\frac{\pi}{5}}{1-\tan^2\frac{\pi}{5}}$ និង $\tan\frac{3\pi}{5}=\frac{3\tan\frac{\pi}{5}-\tan^3\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$

គេបាន $\frac{2\tan\frac{\pi}{5}}{1-\tan^2\frac{\pi}{5}}=-\frac{3\tan\frac{\pi}{5}-\tan^3\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$

ឬ $\frac{2}{1-\tan^2\frac{\pi}{5}}=-\frac{3-\tan^2\frac{\pi}{5}}{1-3\tan^2\frac{\pi}{5}}$ តាង $t=\tan^2\frac{\pi}{5}$

ដោយ $\frac{\pi}{6}<\frac{\pi}{5}<\frac{\pi}{4}$ នោះ $\frac{1}{3}<t<1$

គេបាន $\frac{2}{1-t}=-\frac{3-t}{1-3t}$ នាំឲ្យ $t^2-10t+5=0$

$\Delta'=25-5=20$ គេទាញឫស $t=5-2\sqrt{5}$, $t=5+2\sqrt{5}$

ដោយ $\frac{1}{3}<t<1$ នោះ $t=5-2\sqrt{5}$

គេបាន $\tan^2\frac{\pi}{5}=5-2\sqrt{5}$ នាំឲ្យ $\tan\frac{\pi}{5}=\sqrt{5-2\sqrt{5}}$

ដូចនេះ: $t_1=\sqrt{5-2\sqrt{5}}=\tan\frac{\pi}{5}$ ។

ខ) ស្រាយថា (u_n) ជាស្វ៊ីតធរណីមាត្រមួយ

គេមាន $t_n = \tan u_n$ ដែល $0 < u_n < \frac{\pi}{2}$ គ្រប់ $n \in IN$

គេបាន $t_{n+1} = \tan u_{n+1}$ ដោយ $t_{n+1} = \frac{3t_n - t_n^3}{1 - 3t_n^2}$

នោះ $\tan u_{n+1} = \frac{3\tan u_n - \tan^3 u_n}{1 - 3\tan^2 u_n} = \tan 3u_n$

គេទាញ $u_{n+1} = 3u_n$ គ្រប់ $n \in IN$ ។

ដូចនេះ (u_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q = 3$ ។

គ)គណនា u_n និង t_n ជាអនុគមន៍នៃ n ៖

ដោយ (u_n) ជាស្វ៊ីតធរណីមាត្រមានរេសុង $q = 3$ នោះគេបាន

$u_n = u_1 \times q^{n-1}$ ដោយ $t_1 = \tan u_1 = \tan\frac{\pi}{5}$ នោះ $u_1 = \frac{\pi}{5}$

ដូចនេះ $u_n = \frac{\pi}{5} \times 3^{n-1}$ និង $t_n = \tan\left(\frac{\pi}{5} \times 3^{n-1}\right)$ ។

លំហាត់ទី៥៥

គេឲ្យ $P_n=(\cot a+\cot a)(\cot a+\cot 2a)...(\cot a+\cot(na))$

ចូរបង្ហាញថា $P_n=\dfrac{\sin(n+1)a}{\sin^{n+1}a}$ ។

ដំណោះស្រាយ

បង្ហាញថា $P_n=\dfrac{\sin(n+1)a}{\sin^{n+1}a}$

គេមាន $P_n=\prod_{k=1}^{n}[\cot a+\cot(ka)]$

ដោយ $\cot a+\cot(ka)=\dfrac{\sin(k+1)a}{\sin a\sin(ka)}$

គេបាន $P_n=\prod_{k=1}^{n}\left[\dfrac{\sin(k+1)a}{\sin a\sin(ka)}\right]=\dfrac{1}{\sin^n a}\times\prod_{k=1}^{n}\dfrac{\sin(k+1)a}{\sin(ka)}$

ដោយ $\prod_{k=1}^{n}\dfrac{\sin(k+1)a}{\sin(ka)}=\dfrac{\sin 2a}{\sin a}\cdot\dfrac{\sin 3a}{\sin 2a}\cdots\dfrac{\sin(n+1)a}{\sin(na)}=\dfrac{\sin(n+1)a}{\sin a}$

ដូចនេះ $P_n=\dfrac{\sin(n+1)a}{\sin^{n+1}a}$ ។

លំហាត់ទី៥៦

ចូរគណនាផលគុណ $P_n=\prod_{k=1}^{n}[1-\tan a\tan(ka)]$ ។

ដំណោះស្រាយ

គណនាផលគុណ $P_n=\prod_{k=1}^{n}[1-\tan a\tan(ka)]$

គេមាន $1-\tan a\tan(ka)=\dfrac{\cos a\cos(ka)-\sin a\sin(ka)}{\cos a\cos(ka)}$

$$=\frac{\cos(k+1)a}{\cos a\cos(ka)}$$

គេបាន $P_n=\prod_{k=1}^{n}[1-\tan a\tan(ka)]$

$$=\prod_{k=1}^{n}\left[\frac{\cos(k+1)a}{\cos a\cos(ka)}\right]=\frac{1}{\cos^n a}\times\prod_{k=1}^{n}\frac{\cos(k+1)a}{\cos(ka)}$$

ដោយ $\prod_{k=1}^{n}\dfrac{\cos(k+1)a}{\cos(ka)}=\dfrac{\cos 2a}{\cos a}\cdot\dfrac{\cos 3a}{\cos 2a}\dots\dfrac{\cos(n+1)a}{\cos(na)}=\dfrac{\cos(n+1)a}{\cos a}$

ដូចនេះ $P_n=\dfrac{\cos(n+1)a}{\cos^{n+1}a}$

លំហាត់ទី៥៧

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\frac{a^2}{bc}+\frac{b^2}{ca}+\frac{c^2}{ab}\geq 4\left(\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}\right)$

ដំណោះស្រាយ

ស្រាយថា $\frac{a^2}{bc}+\frac{b^2}{ca}+\frac{c^2}{ab}\geq 4\left(\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}\right)$

តាមទ្រឹស្តីបទស៊ីនូស $a^2=b^2+c^2-2bc\cos A$

ដោយ $b^2+c^2\geq 2bc$ នោះ $a^2\geq 2bc-2bc\cos A=4bc\sin^2\frac{A}{2}$

គេទាញ $\frac{a^2}{bc}\geq 4\sin^2\frac{A}{2}$ (1)

ស្រាយដូចគ្នា $\frac{b^2}{ac}\geq 4\sin^2\frac{B}{2}$ (2) និង $\frac{c^2}{ab}\geq 4\sin^2\frac{C}{2}$ (3)

បូកវិសមភាព (1) (2) និង (3) អង្គនិងអង្គគេបាន ៖

$$\frac{a^2}{bc}+\frac{b^2}{ca}+\frac{c^2}{ab}\geq 4\left(\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}\right)$$ ។

លំហាត់ទី៥៨

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\frac{\cos A}{a^3}+\frac{\cos B}{b^3}+\frac{\cos C}{c^3}\ge\frac{3}{2abc}$ ។

ដំណោះស្រាយ

ស្រាយថា $\frac{\cos A}{a^3}+\frac{\cos B}{b^3}+\frac{\cos C}{c^3}\ge\frac{3}{2abc}$ ។ ។

តាមទ្រឹស្តីបទស៊ីនូស $a^2=b^2+c^2-2bc\cos A$

គេទាញបាន $\frac{2bc\cos A}{a^2}+1=\frac{b^2}{a^2}+\frac{c^2}{a^2}\ge\frac{2bc}{a^2}$ (1) ស្រាយដូចគ្នាដែរ

$\frac{2ac\cos B}{b^2}+1\ge\frac{2ac}{b^2}$ (2) និង $\frac{2ab\cos C}{c^2}+1\ge\frac{2ab}{c^2}$ (3)

បូក (1),(2)និង(3)គេបាន ៖

$$\frac{2bc\cos A}{a^2}+\frac{2ca\cos B}{b^2}+\frac{2ab\cos C}{c^2}+3\ge 2\left(\frac{bc}{a^2}+\frac{ac}{b^2}+\frac{ab}{c^2}\right)\ge 6$$

គេទាញ $\frac{\cos A}{a^3}+\frac{\cos B}{b^3}+\frac{\cos C}{c^3}\ge\frac{3}{2abc}$ ។

លំហាត់ទី៥៩

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\le\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}$

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}$

គេបាន $\frac{a}{b+c}=\frac{\sin A}{\sin B+\sin C}=\frac{2\sin\frac{A}{2}\cos\frac{A}{2}}{2\sin\frac{B+C}{2}\cos\frac{B-C}{2}}$

ដោយ $\sin\frac{B+C}{2}=\sin\left(\frac{\pi}{2}-\frac{A}{2}\right)=\cos\frac{A}{2}$ និង $\cos\frac{B-C}{2}\le 1$

គេទាញបាន $\frac{a}{b+c}\ge\sin\frac{A}{2}$ ។

ស្រាយដូចគ្នាដែរ $\frac{b}{c+a}\ge\sin\frac{B}{2}$ និង $\frac{c}{a+b}\ge\sin\frac{C}{2}$ ។

ដូចនេះ $\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\le\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}$ ពិត ។

លំហាត់ទី៦០

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\frac{a-b}{a+b}=\tan\frac{A-B}{2}\tan\frac{C}{2}$ រួចសរសេររូបមន្តពីរទៀត ដែលស្រដៀងគ្នានេះ ។

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}$

គេបាន $\frac{a-b}{a+b}=\frac{\sin A-\sin B}{\sin A+\sin B}=\frac{2\sin\frac{A-B}{2}\cos\frac{A+B}{2}}{2\sin\frac{A+B}{2}\cos\frac{A-B}{2}}$

ដោយ $\sin\frac{A+B}{2}=\cos\frac{C}{2}$, $\cos\frac{A+B}{2}=\sin\frac{C}{2}$

ដូចនេះ $\frac{a-b}{a+b}=\tan\frac{A-B}{2}\tan\frac{C}{2}$ ។

ដូចគ្នាដែរ $\frac{b-c}{b+c}=\tan\frac{B-C}{2}\tan\frac{A}{2}$ និង $\frac{c-a}{c+a}=\tan\frac{C-A}{2}\tan\frac{B}{2}$

លំហាត់ទី៦១

ត្រីកោណ ABC មួយមានជ្រុង a,b,c ។

ចូរស្រាយថា $\sin\frac{A}{2}\le\frac{a}{2\sqrt{bc}}$ រួចទាញថា $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\le\frac{1}{8}$ ។

ដំណោះស្រាយ

តាមទ្រឹស្តីបទស៊ីនូស $a^2=b^2+c^2-2bc\cos A$ ដោយ $b^2+c^2\ge 2bc$

នោះ $a^2\ge 2bc-2bc\cos A=4bc\sin^2\frac{A}{2}$ ឬ $\sin^2\frac{A}{2}\le\frac{a^2}{4bc}$

ដូចនេះ $\sin\frac{A}{2}\le\frac{a}{2\sqrt{bc}}$ ។

ស្រាយដូចគ្នាដែរ $\sin\frac{B}{2}\le\frac{b}{2\sqrt{ac}}$ និង $\sin\frac{C}{2}\le\frac{c}{2\sqrt{ab}}$

គេបាន $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\le\frac{a}{2\sqrt{bc}}.\frac{b}{2\sqrt{ac}}.\frac{c}{2\sqrt{ab}}=\frac{1}{8}$

ដូចនេះ $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\le\frac{1}{8}$ ។

លំហាត់ទី៦២

គេឲ្យ α,β,γ ជាបីចំនួនពិតដែល $\sin\alpha+\sin\beta+\sin\gamma\geq\frac{3}{2}$

ចូរស្រាយថា $\sin(\alpha-\frac{\pi}{6})+\sin(\beta-\frac{\pi}{6})+\sin(\gamma-\frac{\pi}{6})\geq 0$ ។

ដំណោះស្រាយ

ស្រាយថា $\sin(\alpha-\frac{\pi}{6})+\sin(\beta-\frac{\pi}{6})+\sin(\gamma-\frac{\pi}{6})\geq 0$

យើងឧបមាថា $\sin(\alpha-\frac{\pi}{6})+\sin(\beta-\frac{\pi}{6})+\sin(\gamma-\frac{\pi}{6})<0$ ពិត

សមមូល $\frac{\cos\alpha+\cos\beta+\cos\gamma}{2}>\frac{\sqrt{3}}{2}(\sin\alpha+\sin\beta+\sin\gamma)$

ដោយ $\sin\alpha+\sin\beta+\sin\gamma\geq\frac{3}{2}$

នោះ $\frac{\cos\alpha+\cos\beta+\cos\gamma}{2}>\frac{3\sqrt{3}}{4}$

គេទាញ $\cos\alpha+\cos\beta+\cos\gamma>\frac{3\sqrt{3}}{2}$ ។

ពិនិត្យ $T=\sin(\alpha+\frac{\pi}{3})+\sin(\beta+\frac{\pi}{3})+\sin(\gamma+\frac{\pi}{3})$

$$=\frac{\sin\alpha+\sin\beta+\sin\gamma}{2}+\frac{\sqrt{3}(\cos\alpha+\cos\beta+\cos\gamma)}{2}$$

ដោយ $\sin\alpha+\sin\beta+\sin\gamma\ge\frac{3}{2}$ និង $\cos\alpha+\cos\beta+\cos\gamma>\frac{3\sqrt{3}}{2}$

គេទាញ $T>\frac{3}{4}+\frac{9}{4}=3$ មិន[illegible]ចំនួនពិត α,β,γ

គេមាន $T=\sin(\alpha+\frac{\pi}{3})+\sin(\beta+\frac{\pi}{3})+\sin(\gamma+\frac{\pi}{3})\le 1+1+1=3$

នាំឲ្យការឧបមាខាងលើខុស ។

ដូចនេះ $\sin(\alpha-\frac{\pi}{6})+\sin(\beta-\frac{\pi}{6})+\sin(\gamma-\frac{\pi}{6})\ge 0$ ។

លំហាត់ទី៦៣

គេឲ្យ α និង β ជាពីរចំនួនពិតនៃចន្លោះ $\left[0,\frac{\pi}{2}\right]$ ។

ចូរបង្ហាញថា $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$

លុះត្រាតែ $\alpha=\beta$ ។

ដំណោះស្រាយ

តាងសំណើ $p:\ \sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$

$q:\alpha=\beta$ ។ ដើម្បីស្រាយថា $p\Leftrightarrow q$ ពិត

យើងត្រូវស្រាយថា $p\Rightarrow q$ ពិត និង $q\Rightarrow p$ ពិត ។

យើងស្រាយថា $p\Rightarrow q$ ពិត ៖

តាម $\sin^6\alpha+3\sin^2\alpha\cos^2\beta+\cos^6\beta=1$ គេអាចសរសេរ ៖

$$\left(\sin^2\alpha\right)^3+\left(\cos^2\beta\right)^3+(-1)^3-3\left(\sin^2\alpha\right)\left(\cos^2\beta\right)(-1)=0$$

ដោយប្រើសមភាព ៖

$$a^3+b^3+c^3-3abc=\frac{1}{2}(a+b+c)\left[(a-b)^2+(b-c)^2+(c-a)^2\right]$$

បើគេយក $a=\sin^2\alpha$, $b=\cos^2\beta$, $c=-1$ នោះគេបាន ៖

$$\left[\begin{array}{ll} a+b+c=0 & (1) \\ (a-b)^2+(b-c)^2+(c-a)^2=0 & (2) \end{array}\right.$$

តាម (2) គេទាញ $a=b=c$ ឬ $\sin^2\alpha=\cos^2\beta=-1$ (មិនអាច)

តាម(1)គេបាន$\sin^2\alpha+\cos^2\beta-1=0$ ឬ$\sin^2\alpha=1-\cos^2\beta=\sin^2\beta$

ដោយ $\alpha,\beta\in\left[0,\frac{\pi}{2}\right]$ នោះ $\alpha=\beta$ ។

យើងស្រាយថា $q\Rightarrow p$ ពិត ៖

បើ $\alpha=\beta$ នោះយើងត្រូវស្រាយថា ៖

